ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ ០៣៥/១៦ អ.ល.គ

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមីនា និងទិសដៅខែ មេសា ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៦ ដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៦ )

## I.ស្ថានភាពទូទៅ

នៅក្នុងខែមីនា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលជាដៃគូជាតិនិងអន្តរជាតិ។

អំពីសភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកតាមរបាយការណ៍ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ រកឃើញបទល្មើសជាច្រើនករណី តាមទម្រង់ផ្សេងៗដូចជាការធ្វើអាជីវកម្មផ្លូវភេទ សព្វាកម្ម និងទេសន្តរប្រវេសន៍ ការស្វែងរកការងារ ការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ ដែលកំពុងនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ ត្រូវបានរងគ្រោះជាបន្តបន្ទាប់ និងត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញ ដែលមួយចំនួន បានត្រឡប់មកផ្ទះវិញដោយខ្លួនឯង ខ្លះទៀតបាត់ដំណឹង។ កត្តាទាំងអស់នេះ ជាបញ្ហាប្រឈមដែលគណៈកម្មាធិការជាតិ គ.ជ.ប.ជ ត្រូវរួមសហការជាមួយបណ្តាក្រសួងស្ថាប័ន ដែលជាសមាជិក និងអង្គភាព ដែលពាក់ព័ន្ធព្យាយាមបង្ការទប់ស្កាត់ និងដោះស្រាយរួមគ្នា ។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញការសម្របសម្រួល ជាមួយក្រុមការងារ អន្តរក្រសួង ស្ថាប័ន ព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានាសុំឲ្យមានកិច្ចសហការស្រាវជ្រាវនូវបទល្មើស និងផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ។ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានបំពេញតួនាទី និងភារកិច្ចយ៉ាងមមាញឹក ខិតខំប្រឹងប្រែងបន្តអនុវត្តគ្រប់វិធី និងដឹកនាំជាយុទ្ធសាស្ត្រ តាមផែនការសកម្មភាពជាតិ ឆ្នាំ២០១៤-២០១៨ ដើម្បីបន្តជំរុញសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត ការងារដឹកនាំ ស្តីពីការបង្ការ បង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការដាក់ទណ្ឌកម្មលើជនល្មើស ។

របាយការណ៍ខាងក្រោមជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ចំនួន០១ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងរាជធានី/ខេត្ត ចំនួន២១ច្បាប់ គឺខេត្ត(កោះកុង ,ព្រះសីហនុ ,កំពត , តាកែវ ,កំពង់ស្ពឺ, កណ្តាល , ស្វាយរៀង ,ព្រៃវែង ,ពោធិ៍សាត់ ,ប៉ៃលិន ,បាត់ដំបង ,បន្ទាយមានជ័យ , ឧត្តរមានជ័យ ,ព្រះវិហារ , សៀមរាប , កំពង់ធំ , ក្រចេះ ,ស្ទឹងត្រែង ,រតនគិរី ,មណ្ឌលគិរី និងខេត្តកំពង់ចាម) និងសកម្មភាព របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលទទួលបានលទ្ធផល ដូចខាងក្រោម ៖

## II.លទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

នៅក្នុងខែមីនា ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ បានបន្តយកចិត្តទុកដាក់អនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្តា ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

### ក. ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

**១. ការងារបង្ការ-ទប់ស្កាត់:**

**១.១.ការផ្សព្វផ្សាយ អប់រំ**

នៅក្នុងខែមីនា ឆ្នាំ២០១៦នេះ ការផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធអាជ្ញាធរ និងសមត្ថកិច្ចបានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ទៅតាមគោលដៅចំនួន**៩៧៧**លើក បើប្រៀបធៀបខែមុនមានចំនួន**៦៥០**លើក មានការកើនឡើងចំនួន**៣២៧**លើក ស្មើនឹង**៥០,៣០%** និងមានមនុស្សចូលរួមសរុបចំនួន**៨១,៩៨៥**នាក់ បើប្រៀបធៀបខែមុនមានចំនួន**៧៩,០៦២**នាក់ មានការកើនឡើងចំនួន**២,៩២៣**នាក់ ស្មើនឹង**៣,៧០%** ក្នុងនោះស្ត្រីមានចំនួន**៤៦,៥៩៥**នាក់។ (**ឧបសម្ព័ន្ធទី១**)

**១.២.ការងារបង្ការ-ទប់ស្កាត់**

- យោងលើលទ្ធផលសម្រេចបាន លើការងារបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស ដែលនាយកដ្ឋានជំនាញសមត្ថកិច្ចកងរាជអាវុធហត្ថ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សហការជាមួយស្ថាប័នពាក់ព័ន្ធ ទទួលបានលទ្ធផលសរុបចំនួន**១៨**លើក បើប្រៀបធៀបខែមុនមានចំនួន**៦៨១**លើក មានការថយចុះចំនួន**៦៦៣**លើក ស្មើនឹង**៩៧,៣៥%** មានមនុស្សចំនួន**៣៩១**នាក់ បើប្រៀបធៀបខែមុនមានចំនួន**២,៣១១**នាក់ មានការថយចុះចំនួន**១,៩២០**លើក ស្មើនឹង**៨៣,០៨%** ក្នុងនោះ ស្ត្រី ចំនួន **២០៤** នាក់ ។(**ឧបសម្ព័ន្ធទី២**)

  ○ ស្នងការដ្ឋាននគរបាល**ខេត្តមណ្ឌលគិរី** និង**ខេត្តព្រះវិហារ** បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យា ហាមឃាត់ ការប្រព្រឹត្តអំពើសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវ កម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា,ខារ៉ាអូខេ បានចំនួន៤០គោលដៅ និងមានមនុស្សចំនួន ៥០៩នាក់ (ស្រីចំនួន២៤៥នាក់) ។

  ○ បច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ទាំង២៥ រាជធានី-ខេត្ត មានចំនួន**៧០**គោលដៅក្នុងនោះអំពើជួញដូរមនុស្សចំនួន០៥ គោលដៅនិងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន៦៥គោលដៅ ។

  ○ ស្នងការដ្ឋាននគរបាល**ខេត្តកណ្តាល** បានចុះត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារចំនួន១៩២កន្លែងស្មើនឹង១៩២គោលដៅ នៅក្នុងក្រុងសែនមនោរម្យ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន៨៣៣នាក់ ស្រីចំនួន៥៩១នាក់ ។

  ○ ស្នងការដ្ឋាននគរបាល**ខេត្តក្រចេះ** បានចុះត្រួតពិនិត្យ និងធ្វើកិច្ចសន្យាដល់ម្ចាស់សណ្ឋាគារ ,ផ្ទះសំណាក់, ផ្ទះជួលហាងម៉ាស្សា, ក្លឹបកម្សាន្ត ,ហាងខារ៉ាអូខេ និងនារីបម្រើក្រុមហ៊ុនស្រាបៀរសរុបចំនួន១៩១កន្លែងស្មើនឹង១៩១គោលដៅ ដើម្បីចូលរួមសហការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលមានបុគ្គលិកបម្រើសណ្ឋាគារចំនួន**៧៦៨**នាក់ ស្រីចំនួន**៥០៧**នាក់ ។

  ○ ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាល**ខេត្តស្ទឹងត្រែង** បានចុះត្រួតពិនិត្យ និងបង្ក្រាបការជួល លក់ ថាសវីស៊ីឌីដែលគ្មានទិដ្ឋាការចំនួន០៦កន្លែង ដកហូតបានវីស៊ីឌីរឿងអាសអាភាសដែលនាំឲ្យមានការរំលោភបំពានផ្លូវភេទចំនួន៣៣៤ថាស យកមករក្សាទុកនៅមន្ទីវប្បធ៌មនិងវិចិត្រសិល្បៈខេត្ត ។

  ○ ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាល**ខេត្តសៀមរាប** បានចូលរួមផ្សព្វផ្សាយ ស្តីពីច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស តាមវិទ្យុបានចំនួន០៤លើក ។

-មន្ទីរព័ត៌មានខេត្តសៀមរាប បានសហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមធ្វើជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងកម្មវិធីយើងធ្វើបាន ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយខុសច្បាប់ ។

**២. ការងារការពារ ស្តារនីតិសម្បទាសមាហរណកម្ម និងមាតុភូមិនិវត្តន៍**

**២.១ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ**

-គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ខ.ប.ជ)បានសហការជាមួយ អង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មសរុបបានចំនួន១០៣នាក់ បើប្រៀបធៀបខែមុនមានចំនួន១៥៣នាក់ មានការថយចុះចំនួន៥០នាក់ ស្មើនឹង៣២,៦៧% ក្នុងនោះស្ត្រី មានចំនួន៨២នាក់។ (**ឧបសម្ព័ន្ធទី៣**)

**២.២ សមាហរណកម្ម និងមាតុភូមិនិវត្តន៍៖ ក្នុងខែមីនា ឆ្នាំ ២០១៦ ( គ្មាន )**

**២.៣ ការងារទទួលពលករខ្មែរពីអាជ្ញាធរបរទេស៖**

-ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ និងខេត្តស្វាយរៀងបានទទួលការសម្ភាសពលរដ្ឋខ្មែរ ដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត និងច្រកទ្វារអន្តរជាតិបាវិត មានចំនួន៤,១៥៥នាក់(ស្រីចំនួន១,៤០៨នាក់) អនីតិជនចំនួន៣០៨នាក់ (ស្រីចំនួន១១១នាក់) ។

- ស្នងការដ្ឋាននគរបាលខេត្ត បន្ទាយមានជ័យ មានចំនួន៤,១០៩នាក់ (ស្រីមានចំនួន១,៣៧០នាក់) អនីតិជនចំនួន២៧៩នាក់ (ស្រីចំនួន១៣២នាក់) ។
- ស្នងការដ្ឋាននគរបាលខេត្ត ស្វាយរៀង មានចំនួន៤៦នាក់ (ស្រីមានចំនួន៣៨នាក់) អនីតិជនចំនួន២៩នាក់ (ស្រីចំនួន២១នាក់) ។

-មានប្រជាពលរដ្ឋខ្មែរចំនួន១១៦នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជាវិញ។ ក្រោយធ្វើការសម្ភាសរួច ពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

**៣. ការងារអនុវត្តច្បាប់**

**-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស**

នាយកដ្ឋានជំនាញនិងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេសខិតខំតាមដានស្រាវជ្រាវបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន០៥ករណី/០៩ករណី(បើប្រៀបធៀបខែមុនថយចុះ០៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន០៥នាក់ (ស្រីចំនួន០២នាក់)(ក្នុងនោះជនជាតិឥណ្ឌាចំនួន០១នាក់) សង្គ្រោះជនរងគ្រោះបានចំនួន១៦នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន០២នាក់ ,អាយុពី១៥-១៧ឆ្នាំចំនួន០៥នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន០៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១២នាក់ និងចំនួន០៤នាក់ទៀត ប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

➢ **អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

សរុបចំនួន០៥ករណី/០៦ករណី ជនសង្ស័យចំនួន០៥នាក់(ស្រី០២នាក់)ជនរងគ្រោះចំនួន១៦នាក់ អាយុក្រោម១៥ឆ្នាំចំនួន០២នាក់ ,អាយុពី១៥-១៧ឆ្នាំចំនួន០៥នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន០៩នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១២នាក់ និងចំនួន០៤នាក់ ទៀតប្រគល់ឲ្យគ្រួសារគ្រប់គ្រងវិញ )។

| | |
|---|---|
| -សញ្ចារកម្ម | ០១ករណី ជនសង្ស័យ ០១នាក់ |
| -សញ្ចារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | ០២ករណី ជនសង្ស័យ ០២នាក់ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ករណី ជនសង្ស័យ ០២នាក់ |

### ៤. ការងារកិច្ចការយុត្តិធម៌

តាមទិន្នន័យដែលបានទទួលពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងខែមីនា ឆ្នាំ២០១៦នេះ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**ក. លទ្ធផលចំណាត់ការ៖**

**ក-១ ចំណាត់ការរបស់អយ្យការរាជធានី-ខេត្ត៖**

- សំណុំរឿងសរុបមានចំនួន៣៤រឿង៖
  - ចាត់ការរួច ចំនួន១៦រឿង
  - កំពុងចាត់ការបន្ត ចំនួន១៨រឿង
- ជនល្មើសសរុបមានចំនួន៣៧នាក់ (ស្រីចំនួន០៥នាក់) ក្នុងនោះមាន ៖
  - នីតិជន សរុបចំនួន៣៥នាក់ ស្រី ចំនួន០៥នាក់
  - អនីតិជន សរុបចំនួន០២នាក់

**ក-២ ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត៖**

- សំណុំរឿងសរុបមានចំនួន៤០រឿង៖
  - ចាត់ការរួច ចំនួន០៧រឿង
  - កំពុងចាត់ការបន្ត ចំនួន៣៣រឿង
- ជនត្រូវចោទសរុបចំនួន៦១នាក់ (ស្រីចំនួន២៣នាក់) ក្នុងនោះមាន៖
  - នីតិជន សរុបចំនួន៤៤នាក់ ស្រី ចំនួន១៦នាក់
  - អនីតិជន សរុបចំនួន១៧នាក់ ស្រី ចំនួន០៧នាក់
- ឃុំខ្លួនបណ្តោះអាសន្នជានីតិជន ចំនួន២២នាក់
- នៅក្រៅឃុំបណ្តោះអាសន្នជានីតិជន ចំនួន២៩នាក់

**បញ្ជាក់៖** ជនត្រូវចោទចំនួន១០នាក់ មិនបានបញ្ជាក់អំពីការឃុំខ្លួន ឬនៅក្រៅឃុំនោះទេ ។

- ជនត្រូវចោទជាជនបរទេសសរុបចំនួន១២នាក់ (ស្រីចំនួន០៩នាក់) ក្នុងនោះមាន៖
  - នីតិជន សរុបចំនួន០៩នាក់ ស្រី ចំនួន០៦នាក់
  - អនីតិជន សរុបចំនួន០៣នាក់(ស្រី)
- ឃុំខ្លួនបណ្តោះអាសន្នជនបរទេសជានីតិជន សរុបចំនួន០៧នាក់ ស្រី ចំនួន០៤នាក់

**ក-៣ ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ៖**

- សំណុំរឿងសរុបចំនួន៤៩រឿង៖

- ចាត់ការរួច ចំនួន០៨រឿង
- កំពុងចាត់ការបន្ត ចំនួន៤១រឿង

• ជនជាប់ចោទសរុបចំនួន៦១នាក់ (ស្រីចំនួន១៨នាក់)ក្នុងនោះមាន៖
  - នីតិជន សរុបចំនួន៤៣នាក់ ស្រី ចំនួន១០នាក់
  - អនីតិជន សរុបចំនួន០១នាក់
  - នីតិជន(ជនបរទេស)សរុបចំនួន១៧នាក់ ស្រី ចំនួន០៨នាក់

• នៅក្នុងឃុំសរុបចំនួន៤៦នាក់ (ស្រីចំនួន១១នាក់) ក្នុងនោះមាន៖
  - នីតិជន សរុបចំនួន៤៣នាក់ ស្រី ចំនួន១០នាក់
  - នីតិជន(ជនបរទេស)សរុបចំនួន០៣នាក់ ស្រី ចំនួន០១នាក់

• នៅក្រៅឃុំចំនួន២១នាក់ (ស្រីចំនួន១១នាក់) ក្នុងនោះមាន៖
  - នីតិជន សរុបចំនួន១៧នាក់ ស្រី ចំនួន០៨នាក់
  - អនីតិជន សរុបចំនួន០១នាក់
  - នីតិជន(ជនបរទេស)សរុបចំនួន០៣នាក់(ស្រី)

**៥. ការងារសហប្រតិបត្តិការអន្តរជាតិ**

**+គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៖**

-បានជួបពិភាក្សាការងារជាមួយលោក ស៊ីមម៉ុន ហ្វីលលូស ភារៈធារីរបស់ ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ស្តីពីសេចក្តីព្រាងទៅលើឯកសារពាក់ព័ន្ធក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកោះបាលី ប្រទេសឥណ្ឌូនេស៊ី នៅក្រសួងមហាផ្ទៃ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ។

-បានអញ្ជើញ ចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី ស្តីពីកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (Bali Process Ministerial Conference on People Smuggling, Trafficking in Persons and Related Crimes) ដែលសហការរៀបចំដោយរដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី និងរដ្ឋមន្ត្រីការបរទេសអូស្ត្រាលី នៅកោះបាលីប្រទេស ឥណ្ឌូនេស៊ី មានប្រតិភូចូលរួមចំនួន ៣០០នាក់ មកពី ៤៨ប្រទេស ។ ក្រៅពីនេះ គ.ជ.ប.ជ បានបន្តសហការយ៉ាង ជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន អង្គភាព និងរាជធានី-ខេត្ត ជាពិសេសអង្គការដៃគូពាក់ព័ន្ធនានា ដោយបានជួបប្រជុំជាមួយអង្គការមួយចំនួនដូចជា UN-ACT, Winrock, IJM និង IOM ដើម្បីពិភាក្សា និងសហការគ្នាក្នុងទិសដៅជំរុញការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព ។

**+ខេត្ត ប៉ៃលិន ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ** បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO. LTD ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០១លើក មានពលករចំនួន២១នាក់ ស្រីចំនួន១២នាក់។

**៦. ការងារពាក់ព័ន្ធនឹងកុមារ**

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារ ជាពិសេសកុមារងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន១៣នាក់ ក្នុងនោះជាកុមារីចំនួន១៣នាក់ ៖

+មន្ទីរសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទារាជធានីភ្នំពេញ ក្រុមការងារលេខាធិការដ្ឋានបានទទួលកុមារីរងគ្រោះចំនួន១៣នាក់ ដោយអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង

ការពារអនីតិជន បានបញ្ជូនទៅអង្គការទឹកចិត្តម្តាយ អង្គការវតនៈអន្តរជាតិ អង្គការកុមារគ្រួសារ អង្គការ សង្គ្រោះ និងថែទាំអន្តរជាតិស៊ីជីភ៣ ។

### ៧. ការងារទេសន្តរប្រវេសន៍

○ តាមទិន្នន័យរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបាន ធ្វើការសម្ភាសពលករខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យ សុំរៀបអាពាហ៍ពិពាហ៍បានចំនួន១២៦គូ និងបានសាកសួរ សុខទុក្ខនារីខ្មែរ ដែលបានរៀបការរួចទៅនៅឯក្រៅប្រទេស ដោយបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់របស់សាមីខ្លួនបាន ចំនួន១៩នាក់ (រស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា) ព្រមទាំងបានសម្ភាសពលករ ពលការិនីរងគ្រោះ ចំនួន០៩នាក់ ក្នុងនោះមាន ៖

-មកពីប្រទេសម៉ាឡេស៊ីចំនួន០៨នាក់ (ទៅដោយខ្លួនឯងចំនួន០៤នាក់ និងទៅតាមរយៈក្រុមហ៊ុនចំនួន០៤នាក់) ។

-មកពីប្រទេសចិនចំនួន០១នាក់ (ទៅតាមរយៈមេខ្យល់) ។

○ តាមទិន្នន័យរបស់នាយដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ពលករទេសន្តរប្រវេសន៍ទៅរកការងារធ្វើ នៅក្រៅប្រទេស ដែលបានគ្រប់គ្រងក្នុងខែមីនា ឆ្នាំ២០១៦ សរុបបានចំនួន២៩៧,៤៩៦នាក់(ស្រីចំនួន ១៣០,១៤០នាក់) អនីតិជន មានចំនួន៦,២៧៦នាក់ (ស្រីចំនួន២,០៣២នាក់ ) ក្នុងនោះស្របច្បាប់ចំនួន១៥៣,៧៥៧នាក់ (ស្រីចំនួន ៧០,៩៣៧នាក់) និងអនីតិជនចំនួន៨៧៨នាក់ (ស្រីចំនួន៣៩៣នាក់) មិនស្របច្បាប់ចំនួន១៤៣,៧៣៩នាក់ (ស្រី ចំនួន ៥៩,២០៣នាក់) និងអនីតិជនចំនួន៥,៣៩៨នាក់ ( ស្រីចំនួន២,០៣២នាក់ ) ។

## ខ.ការងារដឹកនាំសម្របសម្រួល

ការងារដឹកនាំសម្របសម្រួលសរុបរួមបានចំនួន៤៨លើក ក្នុងខែមីនា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និង គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ ។ (**ឧបសម្ព័ន្ធទី៧**)

### +សកម្មភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

-បានជួបពិភាក្សាការងារជាមួយ លោក Oliver Ching លេខាជាន់ខ្ពស់ផ្នែក កិច្ចការនយោបាយ នៃស្ថានទូតសាំង ហ្គាពួរ ប្រចាំកម្ពុជា ស្តីពីវិធានការបង្ការទប់ស្កាត់ ការការពារ និងកិច្ច សហប្រតិបត្តិការពាក់ព័ន្ធនឹងការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស ដែលត្រូវដាក់បញ្ចូលក្នុងរបៀបវារៈកិច្ច ប្រជុំកោះបាលី ប្រទេសឥណ្ឌូនេស៊ី នាចុងខែ មីនា នៅក្រសួងមហាផ្ទៃ ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ។

-បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីជួបសំណេះសំណាលអបអរសាទរខួប លើកទី១០៥ ទិវាអន្តរជាតិនារី៨មី នា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង លោកជំទាវ នៅក្រសួងមហាផ្ទៃ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៦ ។

-បានអញ្ជើញជាអធិបតី ក្នុងពិធីប្រជុំផ្សព្វផ្សាយលទ្ធផលប្រឡងប្រណាំងការ អនុវត្តគោលនយោបាយភូមិឃុំមាន សុវត្ថិភាពឆ្នាំ២០១៥ និងទិសដៅអនុវត្តឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ នៅស្នងការដ្ឋាននគរបាលខេត្តកំពង់ ឆ្នាំង និងបានអញ្ជើញទៅជួបសំណេះសំណាលជាមួយបងប្អូនប្រជាការពារភូមិឃុំ នៅសាលាស្រុករលាប្អៀរ ខេត្ត កំពង់ឆ្នាំង ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបអាពាហ៍ពិពាហ៍រវាង ជនជាតិខ្មែរ និងជនជាតិបរទេស ពិសេស ចិន នៅសាលប្រជុំក្រសួងមហាផ្ទៃ អគារទ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាផ្ទៃក្នុងរបស់ក្រុមការងារជំនាញទាំង៦ ស្តីពីការ បែងចែកផែនការការងារសម្រាប់ការ អនុវត្តក្នុងឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ។

-បានជួបពិភាក្សាការងារជាមួយ លោកវេជ្ជបណ្ឌិត លូល មេកូណេន ប្រធាន បេសកកម្មអង្គការ IOM ប្រចាំកម្ពុជា ស្តីពីការបើកវគ្គបណ្តុះបណ្តាលផ្នែកចិត្តសាស្ត្រសង្គម និងការត្រៀម ខ្លួនរបស់សហគមន៍សម្រាប់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការជាដៃគូសហប្រតិបត្តិការ ស្តីពីកិច្ចការងារស្រាវជ្រាវអំពីការពិនិត្យទីផ្សារ និងឱកាសការងាររបស់ពលករចំណាកស្រុក នៅសាលប្រជុំ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនជាតិបរទេស នៅសាលប្រជុំរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

-បានដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈយោគយល់ រវាងកម្ពុជា-ឥណ្ឌា ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសមាសភាពចូលរួមមកពីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អគ្គលេខាធិការដ្ឋានក្រសួង មហាផ្ទៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅសាលប្រជុំ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការ UN-ACT និង Winrock ពាក់ ព័ន្ធគម្រោងសកម្មភាពបើកវគ្គបណ្តុះបណ្តាលស្តីអំពី គោលការណ៍ណែនាំស្តីពីការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាសមស្រប នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយនាយក និងក្រុមការងារអង្គការ IJM ប្រចាំកម្ពុជា ស្តីពីផែនការសកម្មភាពជាតិរបស់ គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ។

-បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយអង្គការ IOM ស្តីពីការរៀបចំផែនការ សម្រាប់កិច្ចប្រជុំរវាងប្រទេសបញ្ជូន និងប្រទេសទទួល ដែលមាន ៤ប្រទេសគឺ កម្ពុជា ថៃ ភូមា និងឡាវ នៅសាលប្រជុំ គ.ជ.ប.ជ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ។

## ឃ. ការលើកកម្ពស់សមត្ថភាព

### ១.ការបណ្តុះបណ្តាល

+ក្រុមការងារអនុវត្តន៍ច្បាប់ នាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជនបានសហការជាមួយអង្គការ ICMEC បើកវគ្គបណ្តុះបណ្តាលចំនួន០១លើក ស្តីពីបទល្មើសលើកុមារតាមប្រព័ន្ធបច្ចេកវិទ្យា ដែលមានសិក្ខាកាមចូលរួមចំនួន៨៦នាក់ (នៅសណ្ឋាគារសាន់វេ )។

### ២. សិក្ខាសាលា

+ខេត្តតាកែវ បានរៀបចំសិក្ខាសាលាបណ្តាញភូមិសុវត្ថិភាព ស្តីពីវិធានការទប់ស្កាត់ និងការពារអំពើជួញដូរមនុស្ស ចំនួន០១លើក មានអ្នកចូលរួមចំនួន៥០នាក់ ស្រីចំនួន១៩នាក់ គាំទ្រដោយអង្គការ VCAO ។

## III. ការវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង ក្នុងខែមីនា ឆ្នាំ២០១៦ នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្តគ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋានគ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី ភារកិច្ចរួមជាស្រេច។

២.បានដាក់ចុះផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)សម្រាប់រយៈពេល ៥ ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារ ទាំង ៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់និង បង្ក្រាបបទល្មើសជួញដូរមនុស្ស ។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែមានប្រសិទ្ធភាព។

**ខ.ចំណុចសេសសល់ និងនាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ក្រុមការងារអន្តរក្រសួងស្ថាប័ន ព្រមទាំងលេខាធិការដ្ឋានរាជធានី-ខេត្ត មួយចំនួនមិនទាន់បានឆ្លើយតបលទ្ធផលការងារ តាមរយៈរបាយការណ៍តាមការកំណត់ នៅឡើយ ។
- ត្រូវការពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តបន្តទៀត អាស្រ័យដោយមានការផ្លាស់ប្តូរ សមាសភាព និងការរៀបចំជាថ្មីនូវរចនាសម្ព័ន្ធតាមបណ្តាថ្នាក់ ។
- សមត្ថភាព និងធនធានមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់នៅមានកម្រិត ដែលទាមទារឲ្យពង្រឹងបន្ថែម ទើបអាចឆ្លើយតបទៅនឹងសភាពការណ៍នៃបទល្មើស ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ ក្នុងនោះមានជនរងគ្រោះ នៅមិនទាន់ឆ្លើយតបទាន់សភាពការណ៍។
- ការទទួលព័ត៌មាន និងការអប់រំ ផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយសម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញ បោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើតាម។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការខ្វះខាត ព្រមទាំងចំណេះដឹងនិងការអប់រំ របស់ពួកគាត់នៅមានកម្រិតដូច្នេះទើបធ្វើឲ្យពួកគាត់ ធ្វើការសម្រេចចិត្តរួសរាន់ទៅតាមការអូសទាញរបស់ឈ្មួញទុច្ចរិត។
- រចនាសម្ព័ន្ធ នៃគណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន មិនទាន់បានរៀបចំត្រឹមត្រូវច្បាស់លាស់ ក្នុងការធ្វើការតាមដានការងារជាប្រចាំ និងពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយលើការងារថ្នាក់ក្រោមជាតិ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមពេញលេញក្នុងការអនុវត្តយន្តការ និងសកម្មភាពរួមនេះហើយបានធ្វើសកម្មភាពដោយឡែក ដែលមិនឆ្លើយតបនឹងគោលដៅ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## IV.ទិសដៅសម្រាប់ខែមេសា ឆ្នាំ ២០១៦

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និង គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តប្រវេសន៍។

២. បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្តាលអណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមបណ្តាក្រសួង មន្ទីរ ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី កម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុងនិងក្រៅប្រទេស និងស្វែងយល់ពីកត្តារុញច្រាន និងអូសទាញ ដើម្បីរៀបចំផែនការបង្ការទប់ស្កាត់។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគី កម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាង កិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយ កាលពីជំនួប នៅប្រទេសចិន នា ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យ កិច្ចព្រមព្រៀង ទ្វេភាគី កម្ពុជា-ឥណ្ឌា តាមការស្នើសុំរបស់ រដ្ឋាភិបាលឥណ្ឌា។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់ រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល( ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ប្រកបដោយសមធម៌។

១០. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា។

១១. ជំរុញការអនុវត្តច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានា ទៅតាមមុខសញ្ញានៃក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១២. សម្របសម្រួល ពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែក គ្រប់វិស័យ និង រវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ សង្គមស៊ីវិល ផ្នែកឯកជន ដើម្បីអនុវត្ត យុទ្ធសាស្ត្រ ដែលបានគ្រោងទុកក្នុងផែនការជាតិ ផែនការក្រុម និងផែនការរាជធានី/ខេត្ត។

១៣. គាំទ្រ និងពង្រឹងសមត្ថភាព របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត។

១៤. បន្តការងារផ្សព្វផ្សាយ អប់រំ តាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការ យល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបាន ដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ[illegible] ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**

-ឧទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## ការខារផ្សព្វផ្សាយ

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | លើក | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការអនុវត្តន៍ ច្បាប់ | ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង និងខេត្តកំពង់ចាម បានធ្វើការផ្សព្វផ្សាយស្តីពីច្បាប់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទស្ត្រី និងកុមារ ដល់ភូមិឃុំមានសុវត្ថិភាព ដល់ម្ចាស់អា ជីវកម្ម អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូនិងសិស្សានុសិស្ស ។ | ស្នងការដ្ឋាននគរបាលខេត្ត | 330 លើក | 19,135 នាក់ | 10,069 នាក់ |
| 2 | តាកែវ | បានធ្វើវេទិកាសាធារណៈ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមភូមិ-ឃុំមានសុវត្ថិភាព ដែលមានសមាសភាពចូលរួមមន្ត្រីរាជការ អង្គការសង្គមស៊ីវិល ,កងកម្លាំងប្រដាប់អាវុធ ,អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 33 លើក | 2,561 នាក់ | 1,262 នាក់ |
| 3 | កណ្តាល | ស្រុក ក្រុងបានធ្វើការផ្សព្វផ្សាយបញ្ហាជួញដូរមនុស្ស និងការធ្វើចំណាក់ស្រុកពិគ្រោះយោបល់ស្ត្រី និងកុមារជូនដល់ប្រជាពលរដ្ឋនិងបានធ្វើវេទិការសារធារណៈ ភូមិឃុំមានសុវត្ថិភាព ដល់បណ្តាភូមិឃុំ ស្រុកនានា ។ | ស្នងការដ្ឋាននគរបាលខេត្ត | 35 លើក | 6,469 នាក់ | 3,510 នាក់ |
| | | មន្ទីរអប់រំយុវជន និងកីឡាបានផ្សព្វផ្សាយច្បាប់ស្តីពីការជួញដូរមនុស្ស ជូនដល់ប្រជាពលរដ្ឋនៅតាមបណ្តាក្រុង ស្រុក | មន្ទីរអប់រំ យុវជន និងកីឡា | 6 លើក | 914 នាក់ | 405 នាក់ |
| | | ក្រុមការងារថ្នាក់ស្រុក បានសហការជាមួយអង្គការ WVC គម្រោង PADEE បានផ្សព្វផ្សាយអប់រំ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង អង្គការ WVC | 6 លើក | 276 នាក់ | 160 នាក់ |
| 4 | កោះកុង | អធិការក្រុង/ស្រុកសហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើការផ្សព្វផ្សាយនិងធ្វើវេទិការសាធារណៈ ស្តីពីការអនុវត្តន៍ គោលនយោបាយភូមិឃុំមានសុវត្ថិភាពនិងការលប់បំបាត់ការជួញដូរមនុស្ស នៅតាមឃុំសង្កាត់ ។ | ស្នងការដ្ឋាននគរបាលខេត្ត | 12 លើក | 465 នាក់ | 254 នាក់ |
| 5 | ឧត្តមានជ័យ | ការិយាល័យជំនាញបានសហការជាមួយកម្លាំងនគរបាល ក្រុងសំរោង ស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកបន្ទាយអំពិល ស្រុកចុងកាល និងអាជ្ញាធរមូលដ្ឋាន បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សា ក្នុងគ្រួសារបានសហការជាមួយគណៈកម្មាធិការពិគ្រោះយោបល់ស្រី ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។ | ស្នងការដ្ឋាននគរបាលខេត្ត | 1 លើក | 35 នាក់ | 20 នាក់ |
| 6 | បាត់ដំបង | ក្រុមការងារគណៈបញ្ជាការឯកភាពបានចុះផ្សព្វផ្សាយ និងធ្វើវេទិការសារធារណៈភូមិឃុំមាន សុវត្ថិភាព ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាជន។ | ស្នងការដ្ឋាននគរបាលខេត្ត | 296 លើក | 21,652 នាក់ | 10,891 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ស្ទឹងត្រែង | បានបញ្ជ្រៀបការទប់ស្កាត់ការអំពើជួញដូរមនុស្ស តាមរយៈសាលារៀននៅក្នុងខេត្តស្ទឹងត្រែងអោយដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងពិសេសការធ្វើចំណាក់ស្រុកដោយសុវត្ថិភាព ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 4 | 273 នាក់ | 137 នាក់ |
| 8 | សៀមរាប | លោកជទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងក្រុមការងារបានរៀបចំវេទិកាផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើ អាជីវកម្មផ្លូវភេទ ដល់ថ្នាក់ដឹកនាំមន្ត្រីរាជការ ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សទូទាំង ស្រុកអង្គជុំ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 150 នាក់ | គ្មាន នាក់ |
| 9 | ពោធិ៍សាត់ | បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមភូមិឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅ ក្រុងពោធិ៍សាត់ , ស្រុកក្រគរ , កណ្តៀង ,ភ្នំក្រវាញ ,បាកាន និងស្រុកវាលវែង ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 170 លើក | 22,999 នាក់ | 16,385 នាក់ |
| | | បានបញ្ជ្រាបវេទិកាសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅស្រុកបាកាន និងស្រុកក្រគរ ។ | | 4 លើក | 861 នាក់ | 352 នាក់ |
| 10 | ក្រចេះ | ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចុះផ្សព្វផ្សាយ ស្តីពីសិទ្ធកុមារ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋចំនួន០២ស្រុក គឺស្រុកសំបូរ និងស្រុកចិត្របុរី ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 8 លើក | 331 នាក់ | 201 នាក់ |
| 11 | រតនៈគីរី | មន្ទីការងារបណ្តុះបណ្តាលវិជ្ជាជីវៈបានសហការជាមួយក្រុមហ៊ុន ធ្វើអធិការកិច្ច ការងារនិហធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីការងារ នីតិវិធីការចេញទៅបំរើការងារដោយស្របច្បាប់នៅសារធារណៈកូរ៉េក្រោមប្រពន្ធ័អនុញ្ញាតមុខរបរ ( E P S )និងផ្សព្វផ្សាយអំពីការធ្វើចំណាក់ស្រុកដោយខុសច្បាប់ ។ | មន្ទីរកិច្ចការនារីខេត្ត អង្គការ | 17 លើក | 230 នាក់ | 60 នាក់ |
| 12 | ព្រះវិហារ | បានផ្សព្វផ្សាយច្បាប់តាមរយៈវេទិកាសាធារណៈ ស្តីពីការលើកកម្ពស់ការយល់ដឹង អំពីច្បាប់ប្រឆាំងអំពើអាស អំពើអាណាចារ ការជួញដូរមនុស្ស និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ បញ្ជ្រាបដល់ភូមិ-ឃុំមានសុវត្ថិភាព ដែលមានមន្ត្រីរាជការ និងប្រជាពលរដ្ឋចូលរួម ។ | ស្នងការដ្ឋាននគរបាលខេត្ត | 37 លើក | 4,554 នាក់ | 2,332 នាក់ |
| 13 | ព្រះសីហនុ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានសហការជាមួយ សាលាខេត្ត ព្រះរាជអាជ្ញាខេត្ត ស្នងការដ្ឋានខេត្ត មន្ទីកិច្ចការនារីខេត្ត អង្គការម្លប់តាប៉ាង អង្គការអេផល បានបើកវគ្គ ផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំបើជួញដូរមនុស្ស និងកិច្ចការពារស្ត្រី និងកុមារនៅស្រុកព្រៃនប់ ខេត្តព្រះស៊ីហនុ ខែ មិនា ២០១៦ និង១៦ មិនា នៅភូមិសំរុង និងភូមិ អណ្តូងថ្ម ។ | គណៈកម្មាធិការ គ.ខ.ប.ជ | 6 លើក | 307 នាក់ | 161 នាក់ |
| | | ក្រុមការងារបានចូលរួមផ្សព្វផ្សាយវេទិកាសារធារណៈភូមិឃុំមានសុវត្ថភាព ដល់កំលាំងសមត្ថកិច្ច មន្ត្រីរាជការ អង្គការ សង្គមស៊ីវិល លោកគ្រូ /អ្នកគ្រូ និងប្រជាជន ។ | | 11 លើក | 773 នាក់ | 396 នាក់ |

សកម្មភាពសរុបចំនួន:977 លើក

មនុស្សសរុបចំនួន: 81,985 នាក់

ស្រីសរុបចំនួន: 46,595 នាក់

## ឧបសម្ព័ន្ធទី២

## ការទារបង្ការទប់ស្កាត់

| ល.រ | អង្គភាព | សកម្មភាព | អ្នកពាក់ព័ន្ធ | កន្លែង/ គោលដៅ | មនុស្សសរុប | ស្ត្រី |
|---|---|---|---|---|---|---|
| 1 | កណ្តាល | ក្រុមការងារ ស្រុក ក្រុង បានធ្វើការប្រជុំជាមួយមន្ត្រីពាក់ពន្ធ័ ជំរុញដល់ក្រុមការងារឃុំសង្កាត់ដើម្បីត្រួតពិនិត្យជនខិលខូចមួយចំនួន ការធ្វើចំណាក់ស្រុកការលប់បំបាត់ពលកម្មកុមារ | - មន្ត្រីក្រុង<br>- ក្រុមប្រឹក្សាស្រុក ឃុំ ភូមិ | 3 លើក | 182 នាក់ | 109 នាក់ |
| 2 | បន្ទាយមានជ័យ | កំលាំងការិយាល័យជំនាញសហការជាមួយវិរសេនាតូច នគរបាលការពារព្រំដែនគោក ៨១៥និងនគរបាលប៉ុស្តិ៍បឹងបេង ស្រុកម៉ាឡៃ បានធ្វើការហាមឃាត់ ពលរដ្ឋធ្វើចំណាក់ស្រុកខុសច្បាប់ បកពីខេត្តសៀបរាម មកធ្វើការអប់រំ រួចអោយត្រឡប់ទៅលំនៅដ្ឋានវិញ | ស្នងការនគរបាលខេត្ត | 1 លើក | 20 នាក់ | 11 នាក់ |
| 3 | បាត់ដំបង | កម្លាំងនគរបាលនៃវរៈការពារព្រំដែនគោកលេខ ៨១៧ ,៨១៩, ៨២៣ ,៣១០ បានចេញល្បាតតាមខ្សែបន្ទាត់ព្រំដែនភូមិសាស្រ្តរបស់ខ្លួន ហើយបានទប់ស្កាត់ប្រជាពលរដ្ឋឆ្លងដែន ខុសច្បាប់ និងបានអប់រំណែនាំឲ្យប្រជាពលរដ្ឋទាំងនោះវិលត្រឡប់ទៅស្រុកកំណើតវិញ ។ | ស្នងការនគរបាលខេត្ត | 3 លើក | 13 នាក់ | 7 នាក់ |
| 4 | ស្ទឹងត្រែង | ស្នងការរដ្ឋាននគរបាលខេត្ត បានទប់ស្កាត់ប្រជាពលរដ្ឋមកពីខេត្តពោធិ៍សាត់បំរុងឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសឡាវ(ធ្វើការនៅក្រុមហ៊ុន វារីអគ្គីសនី) អោយត្រឡប់ទៅផ្ទះវិញ ។ | ស្នងការរដ្ឋាននគរបាលខេត្ត | 1 លើក | 10 នាក់ | គ្មាន នាក់ |
| 5 | កំពត | បានរៀបចំវេទិការសារធារណៈស្តីពីការធ្វើចំណាក់ស្រុកប្រកបដោយសុវត្ថិភាពនៅស្រុមឈូក | មន្ទីកិច្ចការនារី | 1 លើក | 63 នាក់ | 27 នាក់ |
| 6 | ស្វាយរៀង | បន្តផ្សព្វផ្សាយអំពីសេចក្តីណែនាំលេខ០០៥ របស់អគ្គស្នងការនគរបាលជាតិ ដល់ម្ចាស់អាជីវកម្មសង្ស័យពាក់ព័ន្ធបទល្មើសផ្លូវភេទ ទៅដល់បណ្តាអាជីវកម្ម ខារ៉ាអូខេ ផ្ទះសំណាក់ ផ្ទះដួល ម៉ាស្សាកោសជប់ ផ្ទះលក់ការហេ្វ និងដួលលក់វីស៊ីឌី ធ្វើនៅក្រុងស្វាយរៀង និងក្រុងបាវិត បានចុះផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធញ្ញរើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក់ស្រុក ដល់មន្ត្រីនគរបាលយុត្តិធម៌ | ស្នងការរដ្ឋាននគរបាលខេត្ត | 9 លើក | 103 នាក់ | 50 នាក់ |

សកម្មភាពសរុប: 18 លើក

មនុស្សសរុបចំនួន: 391 នាក់

ស្រីសរុបចំនួន: 204 នាក់

## ឧបសម្ព័ន្ធទី៣

## ការងារការពារស្តារនីតិសម្បទា ជនរងគ្រោះ

| ល.រ | អង្គភាព | សកម្មភាព | ចំនួនមនុស្ស | ស្រី |
|---|---|---|---|---|
| 1 | រាជធានីភ្នំពេញ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលនារីរងគ្រោះដោយសារអំពើជួញដូរមនុស្ស ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនក្រុង បញ្ជូនទៅស្នាក់នៅក្នុងមណ្ឌលអង្គការក្តីសង្ឃឹម និងយុត្តិធម៌ និងអង្គការបណ្តាញ ស្ត្រីរួមគ្នា ដើម្បីអប់រំណែនាំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | 12 នាក់ | 12 នាក់ |
| 2 | បន្ទាយមានជ័យ | បុគ្គលិកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានជួយសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ទៅស្នាក់នៅក្នុងមណ្ឌលស្តារនីតិសម្បទា ដើម្បីអប់រំណែនាំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | 6 នាក់ | 2 នាក់ |
| | | បុគ្គលិកមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលជួយសង្គ្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្សទៅនៅក្នុងមណ្ឌលស្តារនីតិសម្បទារយៈពេលខ្លី ដើម្បីបានអប់រំណែនាំ និងទទួលសេវា សោហ៊ុយធ្វើដំណើរត្រឡប់ទៅផ្ទះវិញ។ | 4 នាក់ | 2 នាក់ |
| 3 | បាត់ដំបង | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបានសហការជាមួយអង្គការទស្សនៈពិភពលោក ចុះបញ្ចប់នូវករណីប្រជាពលរដ្ឋរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម ដែលមាននៅក្នុងស្រុកបាណន់ ,បវេល ,ថ្មគោល ,កំរៀង និងស្រុកមោងឫស្សី ។ | 7 នាក់ | 7 នាក់ |
| | | -បានសហការជាមួយអង្គការវេតនៈអន្តរជាតិ សមាហរណកម្មស្ត្រី និងកូនតូចម្នាក់ ដែលរងគ្រោះដោយការជួញដូរកម្លាំង ពលកម្មមកពីប្រទេសម៉ាឡេស៊ី ឲ្យចូលទៅរស់នៅក្នុងសហគមន៍មូលដ្ឋានវិញ ។ បានសហការជាមួយអង្គការ HOPE for JUSTICE សមាហរណកម្មស្ត្រី និងកូនតូចម្នាក់ ដែលរងគ្រោះដោយការជួញដូរ ផ្លូវភេទ នៅខេត្តសៀមរាប ឲ្យចូលទៅរស់នៅក្នុងសហគមន៍មូលដ្ឋានវិញ ។ | 2 នាក់ | 2 នាក់ |
| 4 | ពោធិ៍សាត់ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្ត ទទួលជនរងគ្រោះដោយអំពើជួញ ផ្លូវភេទ ប្រគល់ឲ្យទៅមណ្ឌលអង្គការក្តីសង្ឃឹម និងយុត្តិធម៌(រាជធានីភ្នំពេញ) ដើម្បីបញ្ជូនទៅរកសេវាសុវត្ថិភាព ។ | 6 នាក់ | 6 នាក់ |

| | | | | |
|---|---|---|---|---|
| 5 | សៀមរាប | មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តបានទទួលស្ត្រីរងគ្រោះ ពីករណីសញ្ញាកម្មពីការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជននៃស្នងការនគរបាលខេត្ត ក្នុងនោះបានបញ្ជូនទៅអង្គការក្តីសង្ឃឹមនិងយុត្តិធម៌ចំនួន១០នាក់ អង្គការមេត្រីចំនួន០៤នាក់ និងបានធ្វើការអប់រំ ណែនាំ ឲ្យវិលទៅស្រុកកំណើតវិញចំនួន២១នាក់ ។ | 35 នាក់ | 35 នាក់ |
| 6 | ស្វាយរៀង | បានទទួលប្រជាជនឆ្លងដែនខុសច្បាប់ទៅប្រកបរបរ លក់ឆ្នោត សុំទាន និងធ្វើការកសិដ្ឋាន នៅប្រទេសវៀតណាមចំនួន ១លើក មានចំនួន ១៤គ្រួសារ មនុស្សរួម៣១នាក់ ក្នុងនោះកុមារា ចំនួន២០នាក់ កុមារីចំនួន ០៨នាក់ (តាមច្រកទ្វារអន្តរជាតិបាវិត) ។ | 31 នាក់ | 16 នាក់ |

មនុស្សសរុបចំនួន: 103 នាក់

ស្រីសរុបចំនួន: 82 នាក់

# តារាងឧបសម្ព័ន្ធទី៧
## ភារកិច្ចដឹកនាំសម្របសម្រួល

| លរ. | អង្គភាព | សកម្មភាព | លើក | អ្នកពាក់ព័ន្ធ |
|---|---|---|---|---|
| ១ | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | -បានសហការជាមួយស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ត្រៀមរៀបចំទីកន្លែងប្រជុំនិងទទួលបដិសណ្ឋារកិច្ចគណៈប្រតិភូចិនដែលនឹងអញ្ជើញមកធ្វើកិច្ចព្រមព្រៀង ស្តីពីអាពាហ៍ពិពាហ៍រវាងជនជាតិខ្មែរ និងជនជាតិចិន ។<br>-ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយអង្គការជាដៃគូសហប្រតិបត្តិការ ស្តីពីកិច្ចការងារស្រាវជ្រាវអំពីការពិនិត្យទីផ្សារ និងឱកាសការងាររបស់ពលករចំណាកស្រុក នៅសាលប្រជុំរបស់គណៈកម្មាធិការជាតិ គ ជ.ប.ជ.ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។<br>-បានបំពេញលិខិតចេញ(២១ច្បាប់)និងលិខិតចូល(០៥ច្បាប់)របស់គណៈកម្មធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គជ.ប.ជ. ។<br>-បានបំពេញលិខិតចេញ(២០ច្បាប់)និងលិខិតចូល(១១ច្បាប់) របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងចុះវត្ត មានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី ។<br>-ធ្វើរបាយការណ៍ប្រចាំសប្តាហ៍ និងខែ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងបានធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ ។<br>-រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>-ប្រមូលរបាយការណ៍ខែ និងត្រីមាសទី០១ ឆ្នាំ២០១៦ តាមបណ្តាអន្តរក្រសួង និងរាជធានី ទាំង២៥រាជធានីខេត្ត និងបូកសរុបបញ្ចប់របាយការណ៍ខែកុម្ភៈ ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។<br>-បន្តរៀបចំកែសម្រួលផែនការថវិកាឆ្នាំ២០១៦ សម្រាប់ផ្តល់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។<br>-បន្តរក្សាទុករូបភាព និងសកម្មភាពថ្នាក់ជាតិ និងក្រោមជាតិចូលក្នុងបណ្ណាសារ Wiki ។<br>-បន្តដំណើរការបង្កើត ន Database និងគ្រប់គ្រងទំព័រ facebook របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ ។<br>-ស្រាវជ្រាវព័ត៌មានពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មាន និង comment ផ្សេងៗ ពាក់ព័ន្ធនឹងអំពើជួញដូរ មនុស្សលើទំព័រ facebook ប្រមូលរបាយការណ៍តាមបណ្តារាជធានី/ខេត្ត តាមប្រព័ន្ធ Telegram និង Gmail ។ | ១១ លើក | លេខាធិការដ្ឋាន |

| | | | | |
|---|---|---|---|---|
| | | -បានចូលរួមកិច្ចពិភាក្សាការងាររវាង លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយលោក ស៊ីមម៉ុន ហ្វីលលូស ភារៈធារីរបស់ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា ស្តីពីសេចក្តីព្រាងទៅលើឯកសារ ក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កោះបាលី ប្រទេសឥណ្ឌូនេស៊ី នៅក្រសួងមហាផ្ទៃ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។<br>-ថ្ងៃទី២១-២៤ ខែមីនា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស កោះបាលី ប្រទេសឥណ្ឌូនេស៊ី ។<br>-បានសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីដាក់បញ្ចូលផែនការសកម្មភាពអន្តរក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលជាអនុប្រធាន និងសមាជិកក្រុមការងារបង្ការទប់ស្កាត់ ដើម្បីដាក់បញ្ចូល ជាផែនការរួមសម្រាប់អនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៥-២០១៨ ។<br>-បានពិនិត្យ និងតាមដានព័ត៌មានជាប្រចាំពីសកម្មភាពការបើកវេទិកាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមបណ្តារាជធានី-ខេត្ត តាមរយៈ Telegram ។ | 4 លើក | ក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ |
| | គណៈកម្មាធិការជាតិ គ.ជ.ប.ជ | -ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦ បានចូលរួមអបអរសាទរទិវានារីអន្តរជាតិលើកទី១០៥ នៅខេត្តកំពង់ឆ្នាំង ។<br>-បានជួបប្រជុំក្រុមធ្វើការពិភាក្សាលើផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៦ និងកំណត់ពេលវេលាសំរាប់ការ អនុវត្ត ។<br>-បានជួបពិភាក្សាជាមួយមន្ត្រីជំនាញមកពីក្រសួងសង្គមកិច្ច ស្តីពីការងារធ្វើផែនការសកម្មភាពសម្រាប់ ឆ្នាំ ២០១៦ របស់ក្រុមការងារការពារជនរងគ្រោះ ។<br>-បន្តតាមដានចំនួនពលករ និងជនរងគ្រោះ ដែលបញ្ជូនមកពីប្រទេសក្រៅ ។ | ៤លើក | ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ |
| | | -តាមដានសកម្មភាពការងារ និងប្រមូលរបាយការណ៍ ពាក់ព័ន្ធនឹងការងារអនុវត្តច្បាប់ នៅតាមបណ្តារាជ ធានី-ខេត្ត ។ | ១ លើក | ក្រុមជំនួយកិច្ចការការងារអនុវត្តន៍ច្បាប់ |
| | | -ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ បានណែនាំឈ្មោះ ណាំ ហឿន ភេទស្រី អាយុជាង៤០ឆ្នាំ ទីលំនៅភូមិខ្សោង ឃុំជីបា ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ឲ្យទៅដាក់ពាក្យបណ្តឹងនៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស សុំការអន្តរាគមន៍ជួយសង្គ្រោះប្អូនស្រីគាត់ឈ្មោះ ណាំ ហ៊ន់ អាយុ៣២ឆ្នាំ ត្រូវមេខ្យល់ម្នាក់នៅស្រុកវិហារសួគ៌ ខេត្ត កណ្តាល បោកប្រាស់នាំទៅរៀបការនៅ ចិនតាំងពី២ឆ្នាំមុនហើយត្រូវប្តីវាយធ្វើបាប ឲ្យវិលត្រឡប់មកវិញ ។<br>-បានក្តាប់ព័ត៌មានតាមរយៈលោក យី យុទ្ធវីរៈ មន្ត្រីអង្គការ GVC និងបានធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងសុំគោលការណ៍ ស្តីអំពីប្រជាពលរដ្ឋខ្មែរក្នុងខេត្តបាត់ដំបងចំនួន២០គ្រួសារ ជាសាច់ញាតិ គ្រួសារសពពលករខ្មែរ ដែលបានស្លាប់ក្នុងពេលបំពេញការងារ រីដួបប្រទះឧបទ្ទវហេតុដោយគ្រោះថ្នាក់ ចរាចរណ៍នៅប្រទេសថៃ មានការអាក់អន់ | ៤លើក | ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | គណៈកម្មាធិការជាតិ<br>គ.ជ.ប.ជ | ស្រពន់ចិត្ត ព្រោះនៅពេលដឹកសាកសពមកប្រគល់ឲ្យសាច់ញាតិ ធ្វើការបូជាតាមប្រពៃណីម្តងៗ សាកសពតែងត្រូវបានគេវះពោះទាំងអស់ តែក៏បានដេរភ្ជិតវិញយ៉ាងស្អាត ដែរទើបបញ្ជូនមក (មិនដឹងជាជំនាញបច្ចេកទេសពេទ្យរឺយ៉ាងណាទេ តែសាច់ញាតិសពយល់ថាអាចជា ករណីវះពោះយកគ្រឿងក្នុងទុកធ្វើអ្វីមួយច្រើនជាង) ។ យើងបានបន្តសហការជាមួយលោក យី យុទ្ធវីរៈ ដោយលោកបានផ្តល់ឈ្មោះ និងលេខទូរស័ព្ទសាក្សីដឹងចំនួន២នាក់រស់នៅឃុំព្រៃកលួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង បានប្រាប់ថា កាលគាត់នៅធ្វើសំណង់នៅប្រទេសថៃក្នុងឆ្នាំ២០១៤-២០១៥ ឲ្យតែពេលគាត់ចូលរួមកំដរសពពលករ កម្ពុជាម្តងៗ គាត់តែងតែឃើញមិត្តភក្តិនិង សាច់ញាតិសព ដែលជូនកាលនៅទីនោះស្រាប់ និងជូនកាល ) ទៅពីកម្ពុជាដើម្បីនាំសាកសពមកបូជាឈ្លោះប្រកែកទាស់ទែងជាមួយបុគ្គលិកពេទ្យថៃជាញឹកញយពី រឿ (ងវះពោះសាកសពនេះឯង សាកសពខ្លះមានវះទាំងក្បាលទៀតផង តែមិនដឹងវះដើម្បីអ្វី ហើយដេរភ្ជិត វិញយ៉ាងស្អាត ដោយគ្មានសុំការអនុញ្ញាតិជាមុនទោះជាមានបងប្អូនសាច់ញាតិគេនៅទីនោះក៏ដោយ និង មិនដែលបានឈ្នះក្តីម្តងណាឡើយ ទោះបីធ្លាប់បានប្តឹងសមត្ថកិច្ចថៃក៏ដោយ ។<br>-បានស្រាវជ្រាវ និងប្រមូលព័ត៌មានតាមរយៈគេហទំព័រ និងសារព័ត៌មានផ្សេងៗ រួមមាន៖<br>• អគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃបានចុះពិនិត្យជាក់ស្តែង និងជួបសាកសួរដោយផ្ទាល់ដល់ពលរដ្ឋ ខ្មែរដែលជាកម្មករនេសាទចំនួន៥រូប ដែលកំពុងជាប់ពន្ធនាគារនៅលើកោះគុត ប្រទេសថៃ ដែលត្រូវ បានអាជ្ញាធរថៃចាប់ខ្លួនពីបទរំលោភ និងប្រើអំពើហឹង្សាទៅលើអ្នកទេសចរណ៍បារាំង កាលពីសប្តាហ៍ កន្លងទៅ ។<br>• ស្ថានកុងស៊ុលកម្ពុជាប្រចាំទីក្រុងក្វាងចូវ ប្រទេសចិន បានអន្តរាគមន៍ជួយសង្គ្រោះស្ត្រីខ្មែរ៦នាក់ និង បុរស១នាក់ ដែលស្ត្រីបានចាញ់បោកមេខ្យល់នាំទៅរៀបការនៅប្រទេសចិន តាំងពីឆ្នាំ២០១២ ចំនួន ១នាក់ឈ្មោះ ថត ថាវី អាយុ ៣៥ឆ្នាំ និងតាំងពីឆ្នាំ២០១៣ ចំនួន៥នាក់ឈ្មោះ ង៉ែត សារ៉េត អាយុ ២៩ឆ្នាំ ហួត ហៀង អាយុ២៥ឆ្នាំ ឌឹម សុភ័ណ្ឌ អាយុ២៧ឆ្នាំ រឿង ស៊ីណេង អាយុ២៧ឆ្នាំ អេង សុវណ្ណមុន្នី អាយុ២៤ឆ្នាំ ដោយមូលហេតុត្រូវប្តីធ្វើបាបនិងរស់នៅមិនចុះសម្រុងគ្នា និងឈ្មោះ ថត វិចិត្រ ភេទប្រុស អាយុ២៧ឆ្នាំ ធ្វើការនៅហាងលក់គ្រឿងអលង្កាធ្វើពីថ្ម ក្នុងក្រុងឡុងយាន ខេត្តហ្វូជាន ឲ្យវិលត្រឡប់មកកម្ពុជាវិញក្នុងពេលឆាប់ៗខាងមុខ ។<br>• ការអន្តរាគមន៍ជួយសង្គ្រោះពលការនីខ្មែររងគ្រោះចំនួន៤នាក់ ដែលបានទៅធ្វើការតាមផ្ទះនៅ ប្រទេសម៉ាឡេស៊ី ក្នុងឆ្នាំ២០១៤ ដោយជិះរថយន្តកាត់តាមប្រទេសថៃ ហើយបានជាប់ឃុំឃាំងនៅជំរុំ Balantik camp រដ្ឋ Kedah មានឈ្មោះ ហ៊ិន ស្រីនាង អាយុ២៥ឆ្នាំ អួល ស្រីខួច អាយុ៣៤ឆ្នាំ អាប់ឌុលឡោះ រ៉ាយម៉ា អាយុ២៦ឆ្នាំ និង សំ ភោក អាយុ៤២ឆ្នាំ ឲ្យបានវិលត្រឡប់មកកម្ពុជាវិញនៅ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ។<br>-បានបូកសរុបប្រចាំថ្ងៃនូវចំនួនពលករចំណាកស្រុកខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមកកម្ពុជាវិញ (ពីថ្ងៃ ទី២០ ខែ | | ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ |

| | | | | |
|---|---|---|---|---|
| | | កុម្ភៈ ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៦) សរុបចំនួន ៤.៧៩៦នាក់(ស្រី ១.៧១៨នាក់ កុមារ ៤៧៩នាក់) ក្នុងនោះ៖<br>• តាមច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ចំនួន ៤.៤៥៣នាក់ (ស្រី ១.៥៨៧នាក់ កុមារ ៣៩៧នាក់)<br>• តាមច្រកសំពៅលូន ខេត្តបាត់ដំបង ចំនួន ៣៤៣នាក់ (ស្រី ១៣១នាក់ កុមារ ៨២នាក់) ។ | | |
| | បន្ទាយមានជ័យ | មន្ទីរសង្គមកិច្ចបានបញ្ជូនបុគ្គលិកចំនួន០២នាក់ ចុះទៅសម្ភាសដើម្បីកំណត់អត្តសញ្ញាណ រកមុខសញ្ញាជនរង គ្រោះដោយអំពើជួញដូរមនុស្សក្នុងចំណោមអនីតិជន ដែលអាជ្ញាធរថៃបញ្ជូនមករាល់ថ្ងៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។ | ១លើក | មន្ទីរសង្គមកិច្ច |
| | បាត់ដំបង | -ស្នងការនគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីចំនួន០៣រូប ឲ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន(រាជធានីភ្នំពេញ)សហការរៀបចំដោយអង្គការយូនិសេហ្វ ដែលមានសិក្ខាកាមចូលរួមចំនួន៥០នាក់ ស្រីចំនួន០៧នាក់ នៅថ្ងៃទី០១-០២ ខែ០៣ ឆ្នាំ ២០១៦ ។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានប្រជុំជាមួយអង្គការទស្សនៈពិភពលោក ស្តីពីការ រៀបចំទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា២០១៦ និងការចុះអធិការកិច្ចពលកម្មកុមារនៅតាមសិប្បកម្មឡឥដ្ឋ រៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ។ | ២លើក | ស្នងការដ្ឋាននគរបាលខេត្ត |
| | ប៉ៃលិន | លោកជំទាវ ជា លាក អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គជ បានទទួលគណៈប្រតិភូមកពីខេត្តស្វាយ.ប.ខ. ជ.ប.ខ.សុភាព អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ ដឹកនាំដោយលោកជំទាវ ពៅ រៀងខេត្តស្វាយ រៀង ដើម្បីសិក្សាស្វែងយល់បទពិសោធន៍ នៃការគ្រប់គ្រងពលករចំណាកស្រុក និងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ | ១លើក | លេខាធិការដ្ឋាន គជ.ប.ខ. |
| | ព្រះវិហារ | មន្ទីរកិច្ចការនារីខេត្ត បានបញ្ជូនមន្ត្រីជំនាញចំនួន០៧នាក់ ស្រីចំនួន០៥ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី អំពើជួញដូរនិងការរំលោភបំពានផ្លូវភេទ និងស្តីពីច្បាប់ឯកសារក្បួននីតិវិធីប្រតិបត្តិការរបស់ភ្នាក់ងារនគរ បាលយុត្តិធម៌ បានចំនួន០២ លើក នៅខេត្តបន្ទាយមានជ័យ ។ | ១លើក | មន្ទីរកិច្ចការនារីខេត្ត |
| | កំពត | គណៈកម្មាធិការ គដើម្បីត្រួតពិនិត្យការអនុវត្ត ០៦ដ ខេត្ត បានប្រជុំដល់លេខាធិការដ្ឋាន និងក្រុមការងារទាំង.ប.ជ. ការងារដឹកនាំ គ្រប់គ្រងនិងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងសភាពការណ៍ បទល្មើស និងបង្ការទប់ស្កាត់មុខសញ្ញាអំពើជួញដូរមនុស្ស ព្រមទាំងធ្វើការផ្សព្វផ្សាយអប់រំដល់ប្រ ជាពលរដ្ឋឲ្យយល់ជ្រួតជ្រាបពីល្បិចកល់របស់ជនល្មើស ធ្វើយ៉ាងណាឲ្យពួកគាត់ជៀសផុតពីអំពើជួញដូរមនុស្ស ។ | ១លើក | គណៈកម្មាធិការ គជ .ប.ជ. ខេត្ត |
| | តាកែវ | -បានប្រជុំណែនាំដល់មន្ត្រីលេខាធិការដ្ឋានខេត្ត អំពីការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៦ និងការណែនដល់ទីចាត់ការធនធានមនុស្សរបស់សាលាខេត្ត ក្រុង និងស្រុក ស្តីពីការរៀបចំឡើងវិញនូវមន្ត្រីទទួលបន្ទុកការងារទប់ស្កាត់ និងការប្រឆាំងអំពើជួញដូរមនុស្ស ។ | ២លើក | លេខាធិការដ្ឋាន គជ.ប.ខ. |

| | | | | |
|---|---|---|---|---|
| | | -បានធ្វើរបាយការណ៍ និងការសុំជួយអន្តរាគមន៍ពី សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដើម្បីជួយដល់ពលករខ្មែរចំនួន០៧នាក់ ដែលបានសមត្ថកិច្ចចាប់ខ្លួន ។ | | |
| | កណ្តាល | -លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានប្រជុំប្រចាំត្រីមាសទី១ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០១លើក មានអ្នកចូលរួមចំនួន១០៥នាក់ ស្រចំនួន៧៥នាក់ ។<br>-ក្រុមការងារក្រុង និងស្រុក បានប្រជុំប្រចាំខែ ដើម្បីពង្រឹងសមត្ថភាព ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៣លើក មានអ្នកចូលរួមចំនួន៧៥នាក់ ស្រចំនួន៣៩នាក់ ។<br>-ការិយាល័យប្រឆាំងការជួញដូរមនុស្សនៃស្នងការដ្ឋានខេត្តកណ្តាល បានចាត់កម្លាំងចំនួន០៤រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពីបទល្មើសអំពើជួញដូរលើកុមារ តាមប្រព័ន្ធអ៊ីនធឺណែត នៅសណ្ឋាគារសាន់វ៉េ ។ | ៣លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ |
| | ស្វាយរៀង | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំប្រតិភូក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទៅទស្សកិច្ចសិក្សាដកស្រង់បទពិសោធន៍ នៅខេត្តប៉ៃលិន មានអ្នកចូលរួមចំនួន២១នាក់ ស្រីចំនួន១៥នាក់ មានការគាំទ្រពីអង្គការ ឆាលហ្វានកម្ពុជាប្រចាំខេត្តស្វាយរៀង ។ | ១លើក | លេខាធិការដ្ឋាន គ.ខ.ប.ជ |

សកម្មភាពសរុបចំនួន ៣៦លើក

# តារាងផ្ទៀងផ្ទាត់របាយការណ៍ថ្នាក់ជាតិ ដែលបានទទួល និង មិនបានទទួល

## ចាប់ពីខែ មករា ដល់ខែ មីនា ឆ្នាំ ២០១៦

| ល.រ | អន្តរក្រសួង - ក្រុមការងារ - រាជធានី - ខេត្ត | | មករា | កុម្ភៈ | មីនា | ចំនួនលើក | ត្រីមាសទី១ |
|---|---|---|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រុមការងារបង្ការទប់ស្កាត់ | X | X | X | ០លើក | √ |
| ២ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន | ក្រុមការងារការពារជនរងគ្រោះ | X | X | X | ០លើក | √ |
| ៣ | អគ្គស្នងការនគរបាលជាតិ | ក្រុមការងារអនុវត្តច្បាប់ | √ | √ | √ | ៣លើក | √ |
| ៤ | ក្រសួងយុត្តិធម៌ | ក្រុមការងារកិច្ចការយុត្តិធម៌ | X | X | X | ០លើក | √ |
| ៥ | ក្រសួងការងារ និងបណ្តុះវិជ្ជាជីវៈ | ក្រុមការងារទេសន្តរប្រវេសន៍ | X | X | X | ០លើក | √ |
| ៦ | ក្រសួងកិច្ចការនារី | ក្រុមការងារសហប្រតិបត្តិអន្តរជាតិ | X | X | X | ០លើក | √ |
| ៧ | រាជធានីភ្នំពេញ | | √ | √ | X | ២លើក | X |
| ៨ | កណ្តាល | | √ | √ | √ | ៣លើក | √ |
| ៩ | តាកែវ | | √ | √ | √ | ៣លើក | √ |
| ១០ | កំពត | | √ | √ | √ | ៣លើក | √ |
| ១១ | កែប | | √ | √ | X | ២លើក | √ |
| ១២ | ព្រះសីហនុ | | √ | √ | √ | ៣លើក | √ |
| ១៣ | កោះកុង | | √ | √ | √ | ៣លើក | √ |
| ១៤ | ពោធិ៍សាត់ | | √ | √ | √ | ៣លើក | √ |
| ១៥ | បាត់ដំបង | | √ | √ | √ | ៣លើក | √ |
| ១៦ | ប៉ៃលិន | | √ | √ | √ | ៣លើក | √ |
| ១៧ | បន្ទាយមានជ័យ | | √ | √ | √ | ៣លើក | √ |
| ១៨ | ឧត្តរមានជ័យ | | √ | √ | √ | ៣លើក | √ |
| ១៩ | សៀមរាប | | X | √ | √ | ២លើក | √ |
| ២០ | កំពង់ធំ | | √ | √ | √ | ៣លើក | √ |
| ២១ | ព្រះវិហារ | | √ | √ | √ | ៣លើក | √ |
| ២២ | កំពង់ចាម | | √ | √ | √ | ៣លើក | √ |
| ២៣ | ត្បូងឃ្មុំ | | √ | √ | X | ២លើក | √ |
| ២៤ | ក្រចេះ | | √ | √ | √ | ៣លើក | √ |
| ២៥ | ស្ទឹងត្រែង | | √ | √ | √ | ៣លើក | √ |
| ២៦ | រតនគិរី | | √ | √ | √ | ៣លើក | √ |
| ២៧ | មណ្ឌលគិរី | | √ | √ | √ | ៣លើក | X |
| ២៨ | ព្រៃវែង | | X | √ | √ | ២លើក | √ |
| ២៩ | ស្វាយរៀង | | √ | √ | √ | ៣លើក | √ |
| ៣០ | កំពង់ស្ពឺ | | X | X | √ | ១លើក | √ |
| ៣១ | កំពង់ឆ្នាំង | | √ | X | X | ១លើក | X |
| *អន្តរក្រសួង* | បានផ្តល់របាយការណ៍ | | ១ | ១ | ១ | | ៦ |
| | មិនបានផ្តល់របាយការណ៍ | | ៥ | ៥ | ៥ | | ០ |
| *រាជធានី/ខេត្ត* | បានផ្តល់របាយការណ៍ | | ២២ | ២៣ | ២១ | | ២២ |
| | មិនបានផ្តល់របាយការណ៍ | | ៣ | ២ | ៤ | | ៣ |
| *កំណត់សម្គាល់* | *បានផ្តល់របាយការណ៍* | | √ | √ | √ | | √ |
| | *មិនបានផ្តល់របាយការណ៍* | | X | X | X | | X |